Cambodian


**Protection & Advocacy, Inc.**

**SACRAMENTO LEGAL OFFICE**
100 Howe Avenue, Suite 235 North, Sacramento, CA 95825-8202
Telephone: (916) 488-9950 Fax: (916) 488-9960
Toll Free/TTY/TDD: (800) 776-5746


Note: When this memorandum was originally published, we were known as Protection & Advocacy, Inc. (PAI). In October 2008, we changed our name from PAI to Disability Rights California.

# MEMORANDUM

TO: បុគ្គលជាសាមីខ្លួន
FROM: ភ្នាក់ងារការពារ & គាំទ្រ (Protection & Advocacy, Inc.)
RE: ប្តឹងទាមទារប្រឆាំងនិងរដ្ឋាភិបាលក្រោមច្បាប់ទាមទារព្យសនកម្មកាលីហ្វ័រនីញ៉ា (Filing Claims Against the Government Under the California Tort Claims Act)

ខែថ្ងៃឆ្នាំ : ខែកក្កដា ទី 23 ឆ្នាំ 2001

---

## 1. ការណែនាំ

នៅរដ្ឋកាលីហ្វ័រនីញ៉ា, មុននិងលោកអ្នកអាចប្តឹងទាមទារប្រឆាំងនិងអង្គភាពរដ្ឋការបាន (រដ្ឋ, ខោនធី ឬ រដ្ឋាភិបាលក្រុង) ឬបុគ្គលិករដ្ឋការលើការបាត់បង់ប្រាក់កាស មុនដំបូងលោកអ្នកត្រូវតែដាក់ពាក្យ **ប្តឹងទាមទារ**ដែលត្រឹមត្រូវតាមបទតម្រូវនៃច្បាប់ប្តឹងទាមទារព្យសនកម្មរដ្ឋកាលីហ្វ័រនីញ៉ា។ (រដ្ឋាភិបាលរដ្ឋកាលីហ្វ័រនីញ៉ា លេខក្រមរដ្ឋ 810-996.6 (California Government (Gov't) Code sections 810-996.6) ។ ដោយមានការលើកលែងមានកំរិត, **បណ្តឹងស៊ីវិលចំពោះការបាត់បង់ប្រាក់កាសប្រហែលជាអាចប្តឹងទាមទារប្រឆាំងនិងអង្គភាពរដ្ឋការ លុះត្រាតែការទាមទារនោះបានសរសេរជាអក្សរក្នុងពាក្យប្តឹងដែលសមស្របក្នុងកំឡុងពេលប្រាំមួយខែជាពេលមានកំរិត។** ដូច្នេះ ទោះបីលោកអ្នកមានរបួសគ្រោះថ្នាក់ដល់ខ្លួនប្រាណដោយបុគ្គលិករដ្ឋការ ហើយឥឡូវពុំមានបំណងដាក់ពាក្យបណ្តឹងទេនោះ លោកអ្នកគួរតែគិតដាក់ពាក្យប្តឹងទាមទារដើម្បីការពារសិទ្ធិរបស់លោកអ្នក ហើយនិងរក្សាទុកឱកាសប្តឹងផ្តល់នេះចំហរបាន។

ច្បាប់ California Tort Claims Act (ច្បាប់ប្តឹងទាមទារព្យសនកម្មកាលីហ្វ័រនីញ៉ា) ដាក់របៀបឲ្យលោកអ្នកប្រព្រឹត្តធ្វើតាមនៅពេលលោកអ្នកដាក់ពាក្យប្តឹងទាមទារប្រឆាំងនិង

រដ្ឋការចំពោះការបាត់បង់ប្រាក់កាស។ របាយការណ៍នេះ អធិប្បាយពន្យល់មួយផ្នែកសំខាន់នៃច្បាប់នេះ។ របាយការណ៍នេះបានយោលទៅលើច្បាប់ដែលបានប្រើនៅលើខែថ្ងៃឆ្នាំនៃពេលព្រាងច្បាប់នេះឡើង, ជាការពិតណាស់ ដែលច្បាប់នេះអាចកែប្រែបាន។ មិនតែប៉ុណ្ណោះ បានយោលទៅលើប្រភេទនៃអំពើដែលលោកអ្នកប្ដឹងផ្ដល់នោះផង, របៀបផ្សេងៗទៀតហើយនិងពេលវេលាប្រហែលជាមានដាក់តម្រូវ។ **យើងសុំអោយលោកអ្នកពិភាក្សាជាមួយមេធាវីដែលមានជំនាញការខាងជំពូកច្បាប់ទាក់ទងរឿងរ៉ាវនេះ (ឧទាហរណ៍ ការមានរបួសគ្រោះថ្នាក់ផ្ទាល់ខ្លួន ឬការព្យាបាលដោយធ្វេសប្រហែស) ដើម្បីឲ្យបានទទួលព័តមានជាក់ច្បាស់អំពីបណ្ដឹងរបស់លោកអ្នក ហើយនិងរយៈពេលអាចប្ដឹងបាន។**

## 2. នៅពេលណាដែលចាំបាច់ដាក់ពាក្យបណ្ដឹងទាមទារ

លោកអ្នកអាចជ្រើសប្ដឹងប្រឆាំងនិងរដ្ឋាភិបាលលើជំពូកបញ្ហាច្រើនប្រភេទ។ បញ្ហាខ្លះនោះប្រហែលជារដ្ឋាភិបាលបានល្មើសលើសិទ្ធិរបស់លោកអ្នក ឬរដ្ឋាភិបាលមានបន្ទុកទទួលខុសត្រូវលើការស្លាប់, រងរបួសដល់ខ្លួនប្រាណ ឬបាក់បែកដល់ទ្រព្យសម្បត្តិជាដើម។ បើសិនជាបុគ្គលរដ្ឋការបានធ្វើឲ្យរបួសគ្រោះថ្នាក់ដល់ខ្លួនប្រាណលោកអ្នកការរងរបួសគ្រោះថ្នាក់នេះ ហៅថា "ព្យសនកម្ម" ។ មនុស្សដែលដាក់ពាក្យប្ដឹងទាមទាព្យសនកម្ម ជាទូទៅគឺមនុស្សដែលរងរបួសដល់ខ្លួនប្រាណ ហៅថា អ្នកប្ដឹងទាមទារ។ ក្នុងករណីជាច្រើន លោកអ្នកជាអ្នកប្ដឹងទាមទារ ត្រូវតែបំពេញពាក្យប្ដឹងទាមទារព្យសនកម្ម បើសិនជាលោកអ្នកចង់បានលុយ ឬ "ការបាក់បែក" ពីរដ្ឋាភិបាល។ លេខក្រមរដ្ឋ Gov’t Code sections 905, 906.2 ។

## 3. អ្នកណាអាចដាក់ពាក្យប្ដឹងទាមទារបាន

លោកអ្នកអាចដាក់ពាក្យប្ដឹងទាមទារប្រឆាំងរដ្ឋាភិបាលដោយខ្លួនឯងបាន ឬដាក់ពាក្យប្ដឹងទាមទារក្នុងនាមអោយអ្នកណាម្នាក់ផ្សេងទៀត ដែលបានរបួសគ្រោះថ្នាក់ដល់ខ្លួន។ លេខក្រមរដ្ឋ Gov’t Code sections 910, 910.2 ។ ភាព "រងរបួសគ្រោះថ្នាក់" គឺរួមទាំងមិនមែនត្រឹមតែខ្លួនប្រាណប៉ុណ្ណោះនោះទេ ប៉ុន្តែរាប់ដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ទ្រព្យ) ហើយនិងការល្មើសរំលោភដល់សិទ្ធិដែលបានការពារនោះទៀតផង។

## 4. ដាក់ពាក្យប្តឹងទាមទារដោយរបៀបណា

លោកអ្នកដាក់ពាក្យប្តឹងទាមទារប្រឆាំងនិង**ខោនធី ឬរដ្ឋាភិបាលតំបន់ ឬបុគ្គលិករដ្ឋការ**ណាមួយ ផ្ទាល់ជាមួយក្រុមប្រឹក្សារដ្ឋាភិបាល ឬស្មៀនរដ្ឋតែម្តង។ លោកអ្នកអាចយកពាក្យប្តឹងទាមទារនោះ មកអោយគេផ្ទាល់ ឬផ្ញើមកឲ្យគេតាមប្រៃសណីយ៍។ លេខក្រមរដ្ឋ Gov't Code section 915(a) ។

លោកអ្នកអាចដាក់ពាក្យប្តឹងទាមទារប្រឆាំងនិង**រដ្ឋ ឬភ្នាក់ងាររដ្ឋ ឬបុគ្គលិករដ្ឋការ**ណាមួយ ជាមួយនិងក្រុមប្រឹក្សាត្រួតពិនិត្យរបស់រដ្ឋ (State Board of Control -SBC), ដោយយកពាក្យប្តឹងនោះទៅឲ្យការិយាល័យក្នុងតំបន់របស់ SBC ឬផ្ញើសំណុំរឿងនោះទៅឲ្យការិយាល័យធំតែម្តង។ លេខក្រមរដ្ឋ Gov't Code section 915(b) ។ អាស័យដ្ឋានការិយាល័យធំនៅទីក្រុង Sacramento គឺ :

State Board of Control
Government Claims Branch
P.O. Box 3035
Sacramento, CA 95812-3035
ទូរស័ព្ទ (916) 323-3564 (សម្លេង)
ហ្វាក (916) 323-5768 (ទូរសារ)

លោកអ្នកអាចសុំក្រដាសបំពេញប្តឹងទាមទារ ដោយទូរស័ព្ទមកការិយាល័យ SBC ដោយមិនអស់ លុយលេខ 1-800-955-0045 ឬលោកអ្នកយកក្រដាសនេះតាមរយៈគេហទំព័រកុំព្យូទ័រនៅ www.boc.cahwnet.gov/GovClms.htm។

បើសិនជាលោកអ្នកយកក្រដាសប្តឹងទាមទារមកឲ្យគេផ្ទាល់ ខែថ្ងៃឆ្នាំដាក់ប្តឹងគឺគេរាប់យកខែថ្ងៃឆ្នាំលោកអ្នកយកក្រដាសនោះមកឯល់គេ។ បើសិនជាលោកអ្នផ្ញើមកវិញ ខែថ្ងៃឆ្នាំដាក់ពាក្យប្តឹង គឺខែថ្ងៃឆ្នាំដែលដាក់ផ្ញើមកនោះ – មិនមែនខែថ្ងៃឆ្នាំដែលគេបានទទួលក្រដាសប្តឹងនោះទេ។

បើសិនជាលោកអ្នកសម្រេចចិត្តផ្ញើសំណុំពាក្យទាមទារមក យើងសុំប្រាប់លោកអ្នកឲ្យ**ផ្ញើជាប្រភេទ ស៊ីតទីហ្វាយ ម៉ែល (Certified Mail) ដែលមានប្រកាន់ដៃផ្ញើត្រឡប់មកវិញ។** រដ្ឋាភិបាលខ្លះមានក្រដាសសំរាប់ដាក់ពាក្យប្តឹងទាមទាររបស់គេផ្ទាល់។ លោកអ្នកត្រូវទាក់ទងមកការិយាល័យរបស់រដ្ឋការនោះផ្ទាល់ ដើម្បីស្នើសុំក្រដាសប្តឹងទាមទារនោះ។ ដូចលោកអ្នកបានដាក់បញ្ចូលព៌តមាន ដែលបានតម្រូវអោយមានទាំងអស់រួច

ហើយ (ចូរមើលខាងក្រោម) ក៏ប៉ុន្តែជាការមិនចាំបាច់ ដែលលោកអ្នកត្រូវប្រើក្រដាស ប្ដឹងទាមទាររបស់ភ្នាក់ងាររដ្ឋពិតប្រាកដណាមួយទេ។

## 5. អត្ថបទនៃការបណ្ដឹងទាមទារ

ដោយយោលទៅតាមផ្នែក 910 នៃលេខក្រមរដ្ឋ Government Code, ការប្ដឹងទាមទារ ប្រឆាំងនិងអង្គភាពរដ្ឋការត្រូវតែមានដូចតទៅនេះ :

A. ឈ្មោះរបស់លោកអ្នក (ឈ្មោះអ្នកប្ដឹង) ហើយនិងអាស័យដ្ឋាន;

B. អាស័យដ្ឋានដែលលោកអ្នកទទួលសំបុត្រ;

C. ខែថ្ងៃ, កន្លែងហើយនិងកាលៈទេសៈនៃហេតុការដែលនាំឲ្យមានការប្ដឹងទាមទារ នេះ (ដែល អធិប្បាយពីបុព្វហេតុកើតឡើង ហើយលោកអ្នករបួសគ្រោះថ្នាក់ ដោយរបៀបណា);

D. អធិប្បាយពីការរបួសគ្រោះថ្នាក់, ខូចខាត ឬបាត់បង់;

E. ឈ្មោះបុគ្គលិករដ្ឋការដែលធ្វើឲ្យរបួសគ្រោះថ្នាក់ដល់លោកអ្នក បើសិនជាដឹង;

F. បើសិនជាចំនួនប្ដឹងទាមទារតិចជាង $10,000 ដុល្លារ (រួមទាំងការរប៉ាន់ស្មាន តម្លៃរងរបួសទៅអនាគត) ហើយកត់គូរពីចំនួន; ហើយ

G. បើសិនជាចំនួនប្ដឹងទាមទារច្រើនជាង $10,000 ដុល្លារ លោកអ្នកមិនចាំបាច់ ដាក់ចំនួនពិតប្រាកដនៅលើក្រដាសប្ដឹងទាមទារនោះទេ។ លោកអ្នកត្រូវតែ, ក៏ប៉ុន្តែ ត្រូវបញ្ជាក់បើសំណុំប្ដឹងទាមទារជា "បណ្ដឹងរដ្ឋប្បវេណីកំរិត"។ លេខក្រម រដ្ឋ Gov't Code section 910(f) ហើយលេខក្រម California Civil Code of Procedure sections 85, 86 ។

បើសំណុំប្ដឹងនេះជា "បណ្ដឹងរដ្ឋប្បវេណីកំរិត" គឺវាយោលទៅលើចំនួនប្រាក់ដែល លោកអ្នកប្ដឹងទាមទារ ហើយនិងអ្វីផ្សេងទៀត ដែលលោកអ្នកសុំឲ្យរដ្ឋាភិបាលធ្វើ នោះ។ ជាទូទៅសំណុំបណ្ដឹងរដ្ឋប្បវេណី បើសិនជាមានចំនួនលុយប្ដឹងទាមទារនោះ **តិចជាង $25,000 ដុល្លារ** (មិនគិតពីថ្លៃមេធាវី ហើយតម្លៃផ្សេងៗ) **ហើយ**លោកអ្នក **មិនប្ដឹងទាមទារយកអ្វីផ្សេងទៀត ដូចមានតទៅនេះ** :

1. អធិបញ្ជាអចិន្ត្រៃយ៍ (ជាបទបញ្ជាតុលាបានចេញអោយ ក្រោយពីសវនាការចុង ក្រោយដែលបញ្ជា ឬទុបមិនឲ្យអង្គភាពរដ្ឋការប្ដឹងតបមកវិញ);
2. បញ្ចប់សិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិ;

3. ការអនុវត្តន៍នៃបទបញ្ជាក្រោមក្រមគ្រួសារ (Family Code); ឬ
4. សាលក្រមបកដំណោះស្រាយសំរាលទុក្ខ (ការស្នើសុំឲ្យតុលាការបញ្ចេញខសេចក្តី ដែលបង្កើត សិទ្ធិហើយនិងការទាក់ទងច្បាប់ទម្លាប់នៃភាគីដោយគ្មានការអនុវត្តន៍ច្បាប់), លើកលែងតែមានការអនុញ្ញាតដោយក្រម Code of Civil Procedure section 86 ។

លេខក្រម Code of Civil Procedure section 580 ។

## 6. រយៈពេល

ច្បាប់ California Tort Claims Act បានដាក់ការតឹងតែងលើរយៈពេលដែលលោកអ្នកត្រូវធ្វើតាមនៅពេលដាក់ពាក្យប្តឹងទាមទារប្រឆាំងនិងអង្គភាពរដ្ឋការ។ លោកអ្នកត្រូវដាក់ពាក្យ**ប្តឹងទាមទារចំពោះការរងរបួសផ្ទាល់ខ្លួន** (ដែលបានស្លាប់, រងរបួសដល់ខ្លួនប្រាណ ឬខូចខាតដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន) ក្នុងកំឡុងពេល**ប្រាំមួយខែ**ចាប់ពីខែថ្ងៃរងរបួសនោះមក។ លេខក្រមរដ្ឋ Gov't Code section 911.2 ។

បើសិនជាលោកអ្នកមិនដឹងពីមូលហេតុក្នុងការដាក់ពាក្យបណ្តឹងទាមទារនៅពេលរងរបួសទេ (ឧទាហរណ៍ ការព្យាបាលមិនបានត្រឹមត្រូវ), រយៈពេលប្រាំមួយខែចាប់ផ្តើមនៅត្រង់ចំណុចពេលលោកអ្នកបានដឹងថា ឬក៏គួរបានដឹងនៃមូលហេតុនោះ។ ចូរមើលឧទាហរណ៍, បណ្តឹងរវាង *Whitfield v. Roth* (1974) 10 C.3d 874, 112 Cal Rptr 540។

## 7. ដាក់បណ្តឹងទាមទារយឺតពេល

នៅពេលខ្លះ អ្នកដាក់ពាក្យបណ្តឹងទាមទាររងចាំយូរជាងប្រាំមួយខែបានដាក់ពាក្យបណ្តឹងពីការរងរបួសរបស់ខ្លួន។ ច្បាប់បានចែងចំពោះការប្តឹងទាមទារទាំងពីរប្រភេទនេះដោយឡែកពីគ្នា : បណ្តឹងទាមទារដែលដាក់ពាក្យប្តឹងជាទូទៅយឺតពេល ហើយនិងការដាក់ប្តឹងទាមទារមកយឺតពេល ប៉ុន្តែដាក់ក្រដាសបណ្តឹងនេះមកជាមួយ "ក្រដាសសំរាប់ប្តឹងយឺតពេល"។

បើសិនជាលោកអ្នកមិនដាក់ពាក្យប្តឹងទាមទារលើការរងរបួសក្នុងកំឡុងពេលប្រាំមួយខែចាប់ពីខែថ្ងៃដែលលោកអ្នកបានរងរបួសនោះទេ លោកអ្នកអាចអស់ឱកាសដាក់ពាក្យបណ្តឹង លុះត្រាតែ លោកអ្នកសរសេរសំបុត្រទៅអង្គភាពរដ្ឋការហើយបានទទួលការ "ឆ្លើយបត" ថាអនុញ្ញាតឲ្យដាក់ ពាក្យបណ្តឹងនេះយឺតពេលបាន។ លេខក្រមរដ្ឋ Gov't Code section 911.4(a) ។ នៅក្នុងលិខិតរបស់លោកអ្នក, លោកអ្នកត្រូវតែបញ្ជាក់ពី

មូលហេតុដែលលោកអ្នកមិនបានដាក់ពាក្យបណ្តឹងទាមទារបានក្នុងកំឡុងរយៈពេលប្រាំមួយខែ ចាប់ពីខែថ្ងៃលោកអ្នកបានទទួលរងរបួសនោះមក, ហើយលោកអ្នកត្រូវតែដាក់បញ្ចូលបណ្តឹងទាមទារនោះឲ្យបានជាក់លាក់។ លេខក្រមរដ្ឋ Gov't Code section 911.4(b) ។ មានមូលហេតុបួនអាចយកជាការបាននៅពេលដាក់ពាក្យបណ្តឹងទាមទារយឺត :

1. មានកំហុស, ការមិនយកចិត្តទុកដាក់, ការភ្ញាក់ផ្អើល ឬការធ្វេសប្រហែលលើកលែងឲ្យបាន;
2. មនុស្សមានអាយុក្មេង (អ្នកប្តឹងទាមទារមានអាយុក្មេងនៅកំឡុងពេលប្រាំមួយខែរងចាំនោះ);
3. មនុស្សមិនពេញលក្ខណៈ; ហើយ
4. អ្នកប្តឹងទាមទារនោះបានស្លាប់។

(ចូរមើលលេខក្រមរដ្ឋ Gov't Code section 911.6(b))

លោកអ្នកត្រូវសរសេរសំបុត្រទៅអង្គភាពរដ្ឋការក្នុងកំឡុងពេលសមរម្យ ដែលមិនហួសពីមួយឆ្នាំ ចាប់ពីខែថ្ងៃលោកអ្នកបានរងរបួស ដើម្បីដាក់ពាក្យបណ្តឹងទាមទារយឺតពេល។ លេខក្រមរដ្ឋ Gov't Code section 911.4(b)។ "មូលហេតុ" នៃការពន្យា គឺគិតតាមសំណុំរឿងនិមួយៗ, ហើយនៅក្នុងករណីអោយពន្យាពេលខ្លី ប្រហែលជាគិតថាមិនសមរម្យទេ។ **លោកអ្នកគួរតែដាក់ពាក្យសុំពេលដាក់បណ្តឹងយឺតពេលនេះឲ្យបានឆាប់រហ័ស។**

## 8. តើអ្វីកើតឡើងចំពោះបណ្តឹងទាមទារ ក្រោយពេលបានដាក់ពាក្យប្តឹង រួចមក

ក្រោយពីពេលលោកអ្នកដាក់ពាក្យបណ្តឹងទាមទាររួច, ក្រុមប្រឹក្សា[1] ត្រូវតែធ្វើការឆ្លើយតប (អនុញ្ញាត ឬបដិសេធ, បណ្តឹងទាមទារនេះគេបានបដិសេធនៅលើផ្នែកណាមួយ),

---

[1] លេខក្រមរដ្ឋ Government Code section 900.2 មានន័យថា "ក្រុមប្រឹក្សា" ដូចជា :

(a) នៅក្នុងករណីអង្គភាពរដ្ឋការសាធារណៈក្នុងតំបន់, ក្រុមប្រឹក្សាគ្រប់គ្រងនៃអង្គភាពរដ្ឋការសាធារណៈ ហើយ

(b) នៅក្នុងករណីនៃរដ្ឋវិញ, គឺក្រុមប្រឹក្សាត្រួតពិនិត្យរដ្ឋ (State Board of Control)

ក្នុងកំឡុងពេល 45 ថ្ងៃ។ បើសិនជាក្រុមប្រឹក្សាមិនឆ្លើយបតទេ, បណ្ដឹងទាមទារនេះអាចនឹងបដិសេធនៅលើថ្ងៃទី 45 ។ លេខក្រមរដ្ឋ Gov't Code sections 912.6(a), 912.4(c) ។

## 9. ប្ដឹងប្រឆាំងរដ្ឋការ បើសិនជាបណ្ដឹងទាមទារនេះបដិសេធ

ក្រុមប្រឹក្សាត្រូវតែប្រាប់មកលោកអ្នកពីស្ថានភាពបណ្ដឹងទាមទាររបស់គេ (ឬវាអាចជាការបដិសេធ តាមការមិនបានប្រព្រឹត្តធ្វើតាម)។ បើសិនជាក្រុមប្រឹក្សាបដិសេធពាក្យបណ្ដឹងទាមទារទាំងមូល ឬ ផ្នែកណាមួយ, លោកអ្នកមានរយៈពេល**ប្រាំមួយខែ** ចាប់ពីខែថ្ងៃផ្ញើចេញលិខិតបញ្ជាក់ ដើម្បីប្ដឹងប្រឆាំងនិងអង្គភាពរដ្ឋការ។ លេខក្រមរដ្ឋ Gov't Code sections 913, 945.6(a)(1) ។

បើសិនជាក្រុមប្រឹក្សាមិនបានផ្ដល់ដំណឹងមកលោកអ្នកប្រាប់ពីស្ថានភាពបណ្ដឹងទាមទាររបស់គេទេ (ឬមិនធ្វើសកម្មភាពអ្វី), ការមិនប្រព្រឹត្តធ្វើតាមនេះ អាចចាត់ថាជាការបដិសេធនៃការប្ដឹងទាមទារ (ដូចបានពិភាក្សាខាងលើ) ហើយលោកអ្នកមានរយៈពេល**ពីរឆ្នាំ**ចាប់ពីខែថ្ងៃឆ្នាំបានរបួសគ្រោះថ្នាក់ដើម្បីដាក់ពាក្យប្ដឹងទាមទារ។ លេខក្រមរដ្ឋ Gov't Code section 945.6(a)(2) ។

បើសិនជាលោកអ្នកមិនអាចដាក់ពាក្យបណ្ដឹងបានក្នុងកំឡុងពេលដែលបានចែងនោះទេ ពីព្រោះតែលោកអ្នកជាប់គុក, លោកអ្នកត្រូវតែដាក់ពាក្យបណ្ដឹងក្នុងកំឡុងពេល**ប្រាំមួយខែ** ដើម្បីទាមទារសិទ្ធិធ្វើបែបបទនេះបាន (លោកអ្នកបានចេញពីគុក)។ លេខក្រមរដ្ឋ Gov't Code section 945.6(b) ។

**ម្ដងទៀត ដូចបានពន្យល់ខាងលើមកហើយ, រយៈពេលផ្សេងៗទៀត ហើយនិងពិធីអនុវត្តន៍ទៅនិងសំណុំបណ្ដឹងរបស់លោកអ្នក, ដូច្នេះយើងសូមប្រាប់ថា លោកអ្នកត្រូវទៅពិភាក្សាជាមួយមេធាវី ដើម្បីស្នើសុំព័តមានជាក់លាក់ដែលទាក់ទងទៅនិងស្ថានការរបស់លោកអ្នក។**